THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington**
Superintendent

ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២២

ជូនចំពោះ  ក្រុមគ្រួសារ និងសហគមន៍ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ថ្ងៃនេះជាថ្ងៃបញ្ចប់នៃសប្តាហ៍ទីមួយរបស់ខ្ញុំ ក្នុងនាមជាអគ្គនាយកក្រសួងអប់រំនៃក្រសួងអប់រំដ៏អស្ចារ្យរបស់យើង។ មុនពេលខ្ញុំចែករំលែកការរិះគិត និងគំនិតមួយចំនួនជាមួយលោកអ្នក ដំបូងខ្ញុំចង់និយាយថា ខ្ញុំពិតជាដឹងគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅដែលខ្ញុំបានទទួលពីសិស្ស ក្រុមគ្រួសារ និងសមា ជិកជាច្រើននាក់ទៀត នៃសហគមន៍ហ្វីឡាដែលហ្វ្យ៉ារបស់យើង។ ពីលិខិត និងអ៊ីមែល ដែលលោកអ្នកបានចែករំលែកនៅក្នុងវគ្គជួបគ្នាដំបូង ទៅ "ជំរាបសួរ និងស្វាគមន៍" នៅពេលដែលលោកអ្នកបានជួបខ្ញុំពាសពេញទីក្រុង លោកអ្នកបានធ្វើឱ្យខ្ញុំមានអារម្មណ៍កក់ក្តៅ ហើយខ្ញុំពិតជាអរគុណខ្លាំងណាស់។

ដូចដែលលោកអ្នកបានជ្រាប ខ្ញុំបានបញ្ចេញនូវរបៀបវារៈដ៏មានមហិច្ឆតាសម្រាប់រយៈពេល ១០០ ថ្ងៃដំបូងរបស់ខ្ញុំ ដែលលោកអ្នកអាចស្វែងយល់បន្ថែមនៅក្នុងគេហទំព័រ philasd.org/100days.។ នៅទីនោះ លោកអ្នកអាចបំពេញ ការស្ទង់មតិអំពី ការស្តាប់ & ការស្វែងយល់ របស់យើង ដើម្បីចែករំលែកជាមួយខ្ញុំនូវការយល់ឃើញ និងគំនិតរបស់លោកអ្នកអំពីក្រសួងអប់រំរបស់យើង ហើយលោកអ្នកអាចចុះឈ្មោះសម្រាប់វគ្គស្តាប់ និងស្វែងយល់ នាពេលខាងមុខ។ យើងបានចាប់ផ្តើមយ៉ាងខ្លាំងក្លារួចទៅហើយ ដោយបានបញ្ចប់វគ្គស្តាប់ និងស្វែងយល់ ចំនួន ៧ ក្នុងចំណោមជាង ៨០ វគ្គ ដែលបានគ្រោងទុករហូតដល់ខែ កញ្ញា។ ខ្ញុំមានជាងដប់ពីរវគ្គទៀតដែលបានគ្រោងទុកសម្រាប់សប្តាហ៍ក្រោយ ហើយខ្ញុំរំភើបចិត្តក្នុងការបន្ត ការស្តាប់ និងការស្វែងយល់ នេះ។ គ្រប់សំឡេងទាំងអស់មានសារៈសំខាន់សម្រាប់ខ្ញុំ ហើយខ្ញុំចង់ឮពីមនុស្សជាច្រើន តាមដែលអាចធ្វើទៅបាន ក្នុងប៉ុន្មានសប្តាហ៍ និងខែ ខាងមុខនេះ។

កិច្ចខិតខំប្រឹងប្រែងដ៏សំខាន់មួយទៀតដែលកំពុងដំណើរការគឺ ការរៀបចំផែនការសម្រាប់ការចាប់ផ្តើមក្រុមការងារថ្មីរបស់ខ្ញុំ ដែលនឹងរួមបញ្ចូលអ្នកជំនាញក្នុងស្រុក និងថ្នាក់ជាតិ ព្រមទាំងការស្រាវជ្រាវថ្មីៗ និងការអនុវត្តល្អបំផុត ដើម្បីជួយយើងវាយតម្លៃពីរបៀបដែលយើងអាចដោះស្រាយបញ្ហាដែលក្រសួងអប់រំកំពុងប្រឈម មុខដោយប្រសិទ្ធិភាព និងបំពេញតាម គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និង ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ (Goals and Guardrails) របស់យើង។ ក្រុមនេះនឹងមានអនុគណៈកម្មការចំនួនប្រាំ ដែលស្របតាមផ្នែកសំខាន់ជាងគេដែលបានរៀប រាប់នៅក្នុង ផ្នែកសំខាន់ជាងគេ ក្នុងអំឡុងពេល ១០០ ថ្ងៃ របស់ខ្ញុំ។ ខ្ញុំមានបំណងចាប់ផ្តើមក្រុម ការងារថ្មីនេះក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ ដូច្នេះសូមរង់ចាំព័ត៌មានបន្ថែម។

សូមអរគុណម្តងទៀត ចំពោះការស្វាគមន៍យ៉ាងកក់ក្តៅពីទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ខ្ញុំទន្ទឹងរង់ចាំការងាររួមគ្នារបស់យើង។ សូមរីករាយនៅចុងសប្តាហ៍នេះ សូមថែរក្សាខ្លួន និងរក្សាសុវត្ថិភាព។

ក្នុងភាពជាដៃគូសម្រាប់ក្មេងៗ




Dr. Tony B. Watlington
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា